# បុគ្គលិកសង្គម

**តើអ្នកមានចំណាប់អារម្មណ៍ធ្វើការ ដើម្បីជួយដល់យុវជនដែលបាត់បង់ឱកាស និងក្រុមគ្រួសារពួកគាត់ដែរឬទេ? តើអ្នកចង់ធ្វើការជាមួយក្រុមអ្នកជំនាញ ដែលផ្តល់នូវសេវាសង្គមប្រកបដោយគុណពភាពខ្ពស់ដែរឬទេ? បើមានចំណាប់អារម្មណ៍ អ្នកអាចមកចូលរួមជាមួយយើងបាន!**

អ្នកនឹងចូលរួមជាមួយក្រុមការងាររបស់អង្គការមិត្តសំឡាញ់ ដែលមានអ្នកជំនាញជិត ២៥០នាក់ ធ្វើការជាមួយគ្នា ដើម្បីផ្តល់នូវ សេវាសង្គមជាច្រើនទៅដល់កុមារ និងយុវវ័យដែលបាត់បង់ឱកាស និងក្រុមគ្រួសាររបស់ពួកគេ។ យើងបានបង្កើតក្រុមរថយន្តចល័តពេលយប់ ដើម្បីធានាក្នុងការផ្តល់ការបណ្តុះបណ្តាលជំនាញ ឬការងារ ទៅពួកគាត់ រួមទាំងការគាំទ្រគ្រួសារ និងសហគមន៍ ក្នុងការជួយថែទាំកូនរបស់គាត់។ យើង បានផ្តល់ការបណ្តុះបណ្តាលជំនាញជាច្រើនដូចជា ចុងភៅ និងសេវាកម្មសម្អាងកាយ កាត់សក់ ផ្សារដែក អគ្គីសនី។

**តើអ្នកត្រូវធ្វើអ្វី?**

ក្នុងតួនាទីជា **បុគ្គលិកសង្គម** អ្នកនិងគាំទ្រដល់កុមារ/យុវវ័យ និងក្រុមស្រ្តីបម្រើសេវាកម្សាន្តនៅពេលយប់ ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពកុមារ/ យុវវ័យងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ។

**អ្នកនឹងទទួលខុសត្រូវការងារសំខាន់ៗដូចខាងក្រោម៖**

- ស្វែងរកកុមារ យុវវ័យ គ្រួសារ និងរៀបចំផែនការបើកករណីគ្រប់គ្រងកុមារ យុវវ័យ និងគ្រួសារដោយសហការជាមួយក្រុមពាក់ព័ន្ធ
- ផ្តល់ការពិគ្រោះយោបល់ អប់រំបំណិនជីវិតដល់កុមារ/យុវវ័យ និងក្រុមគ្រួសាររបស់ពួកគេ នៅតាមថ្នល់និងសហគមន៍
- ផ្តល់ការគាំទ្រកុមារ/យុវវ័យដែលងាយរងគ្រោះក្នុងការដោះស្រាយបញ្ហា
- ជំនាញផ្តល់ការគាំទ្រកុមារ/យុវវ័យនិងក្រុមគ្រួសារទៅកាន់សេវាផ្សេងៗ ដូចជាការអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការងារ និងមុខរបរ និងការបញ្ជូនទៅសេវាព្យាបាល។ល។
- ទំនាក់ទំនងជាមួយអាជ្ញាធរដែនដី និងអង្គការពាក់ព័ន្ធ

**យើងត្រូវការអ្នកដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖**

- អ្នកមានបរិញ្ញាបត្រទុតិយភូមិ ឬសង្គមវិទ្យា ចិត្តវិទ្យា កាន់តែប្រសើរ
- អ្នកមានចំណេះដឹងផ្នែកការងារសង្គម ឬការការពារកុមារ
- បទពិសោធន៍ពាក់ព័ន្ធ ០២ឆ្នាំជាមួយការថែទាំកុមារ ឬយុវវ័យ គ្រួសារ និងសហគមន៍
- អ្នកចូលចិត្តធ្វើការងារជាមួយកុមារ/យុវវ័យ និង ការងារសង្គម
- អ្នកមានមានជំនាញក្នុងការទំនាក់ទំនង អាចធ្វើការងារជាក្រុម មានភាពអត់ធ្មត់ ចេះបត់បែន
- អ្នកចេះបើកកងបី និងរថយន្តដឹកអ្នកដំណើរ
- អ្នកអាចធ្វើការពេលយប់ ពីម៉ោង៧:០០នាទីយប់ ដល់ម៉ោង១២:០០នាទីយប់ មួយសប្តាហ៍សម្រាក២ថ្ងៃ

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាស័យដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org។ សូមបញ្ជាក់ពីតួនាទីដែលអ្នកចង់ដាក់ពាក្យ និងប្រាក់បៀវត្សរ៍រំពឹងទុក។ ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦។

បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍។ បេក្ខជនទាំងអស់នឹងត្រូវឆែកប្រវត្តិរូប ដើម្បីអនុលោមតាមគោលការណ៍ កិច្ចការពារប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ(PSEA)។

ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី**១៨ ខែធ្នូ ឆ្នាំ២០២២**។